# មរតកក្បាច់គុន ល្បុក្កតោខ្មែរ

## ស្រាវជ្រាវ និង ចងក្រង

ដោយ

លោក មាស សុខ



ឧបត្ថម្ភបោះពុម្ពដោយ
ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

បោះពុម្ពលើកទី ១ ចំនួន ១.៥០០ ក្បាល

រក្សាសិទ្ធិគ្រប់យ៉ាង

ព.ស ២៥៥១ គ.ស ២០០៧

# បទឧទ្ទិស

ខ្ញុំសូមឧទ្ទិសស្នាដៃស្រាវជ្រាវ ចងក្រង សៀវភៅ **មរតកក្បាច់គុនល្បុក្កតោខ្មែរ** នេះ ជូនចំពោះដូនតាខ្មែរទាំងអស់ ដែលជាអ្នកបង្កើតក្បាច់គុនល្បុក្កតោ ត១គ្នាតាំងពីអតីតកាលរហូតដល់បច្ចុប្បន្ននេះ សូមវិញ្ញាណក្ខ័ន្ធដូនតាដែលបានមរណភាពទៅហើយនោះ បានទៅសោយសុខនៅឋានសុគតិភព និង សូមព្រលឹងដូនតាទាំងអស់តាមបីបាច់ថែរក្សាការពារ ក្បាច់គុនល្បុក្កតោខ្មែរ ឱ្យបានស្ថិតស្ថេរជានិរន្តរ៍ នៅក្នុងសង្គមជាតិខ្មែរតរៀងទៅ ។

សូមគោរពជូនពរពីចម្ងាយចំពោះដូនតា ដែលមានជីវិតរស់នៅគ្រប់ច្រកល្ហក ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលជាអ្នកស្រឡាញ់ ជាអ្នកថែរក្សាក្បាច់គុនល្បុក្កតោ សូមបានជួបប្រទះនឹងសេចក្តីសុខចម្រើន គ្រប់ប្រការ កុំបីឃ្លៀងឃ្លាតឡើយ ។ សូមឱ្យក្បាច់គុនល្បុក្កតោខ្មែរ បានលូតលាស់រីកចម្រើនពាសពេញក្នុងសង្គម ។ សូមឱ្យកូនខ្មែរទាំងអស់ជួយថែរក្សា លើកតម្កើង កេរមរតកដ៏ពិសិដ្ឋនេះ ឱ្យបានល្បីល្បាញដូចក្នុងសម័យអតីតកាល ។

# អារម្ភកថា

ការដែលខ្ញុំខិតខំប្រឹងប្រែងស្រាវជ្រាវ ចងក្រង សៀវភៅ **មរតកក្បាច់គុនល្បុក្កតោខ្មែរ** ដោយខ្ញុំយល់ឃើញថា: ការបាត់បង់នូវតម្លៃណាមួយរបស់សិល្បៈវប្បធម៌ គឺជាការបាត់បង់នៃព្រលឹងជាតិ ដែលធ្លាប់រុងរឿងពីអតីតកាល ។ កេរដំណែលវប្បធម៌ដែលមានពីមុនមក ត្រូវតែរស់ ត្រូវតែមាន ត្រូវតែអភិវឌ្ឍឱ្យស៊ីសង្វាក់គ្នានឹងការរីកចម្រើននៃវិស័យដទៃទៀត ។ ប៉ុន្តែមកដល់ពេលនេះ ក្បាច់គុនល្បុក្កតោខ្មែរ ដែលជាមរតកវប្បធម៌ជាតិយើងដ៏សំខាន់មួយនៅតែឱនថយ ឬក៏ឈានទៅរកការបាត់បង់ទៀតផង ។ ប្រការនេះហើយ ដែលធ្វើឱ្យខ្ញុំសម្រេចចិត្តប្រមូលរាល់ចលនានៃក្បាច់គុននីមួយៗ មកបង្ហាញក្នុងសៀវភៅនេះដើម្បីឱ្យកូនខ្មែរទាំងអស់ជួយរួមចំណែកកសាងថាមពលក្បាច់គុនខ្មែរខ្លាំង ជួយរក្សាឧត្តមភាពក្បាច់គុនកម្រិតខ្ពស់ ដើម្បីជាតិមានមោទកភាព និង ដើម្បីភាពរុងរឿងនៃជាតិ ។

ការបង្ហាញក្បាច់គុនល្បុក្កតោនៅក្នុងសៀវភៅនេះ ពុំទាន់មានលក្ខណៈសុក្រិត្យនៅឡើយទេ ខ្ញុំនៅតែខិតខំសិក្សាស្រាវជ្រាវបន្តទៀត ប៉ុន្តែប្រសិនបើមានខ្វះខាតផ្នែកក្បាច់ណាមួយ សូមមិត្តអ្នកស្នេហាក្បាច់គុនល្បុក្កតោទាំងអស់មេត្តាជួយបំពេញបន្ថែម និង មេត្តាជួយផ្តល់មតិក្នុងន័យកសាង ។

ខ្ញុំសូមអរគុណទុកជាមុន ។

# អត្ថន័យ

- ✳ ក្បាច់គុនល្បុក្កតោខ្មែរ មានប្រយោជន៍ណាស់សម្រាប់ដូនតាយើងពីជំនាន់ដើម ដូចជាៈ ការពារស្រុកភូមិ (ទឹកដី) ប្រយុទ្ធនឹងខ្មាំងសត្រូវ ភាពរហ័សរហួនរឹងមាំ ។ល។
- ✳ ក្បាច់គុនទាំងឡាយមានៈ ក្បាច់គុនដៃ គុនដាវ គុនដំបងខ្លី វែង +គុនកន្សែង + គុនក្រាប់ + គុនកូនតឹង គុនខ្សែគាថា ចំបាប់ ។ល។
- ✳ ក្បាច់ទាំងនោះដក់ជាប់នូវភាពស្លូត បូតរហ័សរហួន មាំទាំ និងមានមេក្បាច់យ៉ាងជាក់លាក់ទៀតផង។ ដូចជាៈ

  - មេការោមមេ ឬពង់ឆែក មេ ១២ កាត់យក ៨
  - មេពង់សក្តិ មេ១២ កាត់យក ៨
  - មេព្រះអាទិត្យទ្រមេឃ មេស្វាស្ទូមែក មេក្រោម ៣ ចំហៀង មេថ្វាយគ្រូ មេគាថាបង់បត់ សោមដាវ មេមហាសែងព្រះអាទិត្យ មេលើកគ្រូ មេមហាហឹង កាត់ដែក មេមហាមេឃទូលព្រះចន្ទ មេឥសីដកដាវ មេកាត់គងជ្រងព្រះអាទិត្យ មេបំបែកខណ្ឌទ្វារប្រាំបី មេផ្កាស្វាយរីក មេកាត់គងរាជសីហ៍សក្តិ មេរំងាប់ជើងទៀន គោរពដាវឯក មេជឹងជ្រងផាត់ពពក មេហនុមានទូលថែប មេព្រះច័ន្ទបាំងឆ័ត្រ មេទ័ពចម្លងដៃ មេទប់ធាក់ភ្លាន មេបីដៃ និងមេទ្រទឹក ហួតព្រលឹង ។ល។

- ✳ ក្បាច់ដំបងខ្លី+វែង មានដំបងចុងមួយ និងដំបងចុងពីរ ដោយមានមេដូចជា : មេរង មេរាយ មេទ្រផ្កាស្វាយ មេសើយលាត់ មេផាត់ប្រមូល មេខ្លាក្រាប មេទ្វារប្រាំបី មេឆ្វៀងកណ្តៀត មេកុកផាត់ មេស្វាហក់ពាំផ្កា មេនាគពាំកែវ មេក្រពើហា មេក្រពើវាត់កន្ទុយ មេនាគពាំកែវគ្រវែងទប់ពពក ។ល។

# របៀបរៀបគ្រឿងរណ្តាប់

* ក្នុងរោងហាត់គុនល្បុក្កតោខ្មែរ មានៈ នៅប្របជញ្ជាំងខាងលិច មានតុដាក់គ្រឿងពិ្ធីការសម្រាប់ឱ្យសិស្សយក ទៀនធូបទៅអុជបូជាព្រះពិស្ណុការរាល់ថ្ងៃ មុនប្រារព្ធរៀន ។
* នៅខាងកើតមិនឆ្ងាយពីរោងប៉ុន្មានមានធ្វើរានម៉ាពថ្នាក់ តម្កល់បាយសី ស្លាជម ទឹកអប់ លាជ ផ្កា ដែលជា គ្រឿងបូជាចំពោះព្រះគ្រូ ។ ក្នុងនោះមាន ស្លាជម ដោតគ្រប់ទិសទាំងប្រាំបី ។
* ដំបូងសិស្សជុំគ្នានៅក្នុងរោង ធ្វើពិធីសែនព្រេនប្រោះព្រំសិស្សទាំងអស់ គ្រូ យកអំបោះជ័យទៅចងគ្រប់ដៃ សិស្ស រួចសិស្សនាំគ្នាអុជទៀនធូប ដោតនៅរានម៉ា ដោយអធិដ្ឋានសុំឱ្យគ្រូចូលមកសណ្ឋិត ឱ្យរៀនឆាប់ចេះចាំ ។

# របៀបហាត់



# ត្រណម

* ត្រណមទីមួយ - សិស្សទាំងអស់ត្រូវតមប្រកួតគ្នាលេង ។

* ត្រណមទីពីរ - ដាច់ខាតមិនឱ្យនាំស្រីចូលរោងហាត់រៀន ។

* ត្រណមទីបី - មិនត្រូវប៉ះពាល់គ្រឿងតង្វាយព្រះពិស្ណុការឡើយ ។

* ត្រណមទាំងនេះ បើមានសិស្សណាប្រព្រឹត្តល្មើស នឹងកើតហេតុផ្សេងៗយ៉ាងធំ មួយរំពេចមិនខាន ។ ជួនមានភ្លើងឆេះរោង ឈឺថ្កាត់ ឬអ្នករាជការរករឿងហេតុ ។



# ក្បាច់ប្រកួតដៃ-ជើង

- ក្បិនក្រហម ប្រើក្បាច់ខ្លាក្រាប
- ក្បិនខៀវ ប្រើក្បាច់ខ្លាសង្គ្រប់ទន្សាយ




- ក្បិនខៀវប្រើក្បាច់ខ្លា សង្គ្រប់ ប្រើជង្គង់ខោកបាក់ភ្នំ សង្គ្រប់មក ក្បិនក្រហម ។
- ក្បិនក្រហម យកក្បាច់ ស្លាបសេដាយស យកកែងបុក ភ្លៅទៅក្បិនខៀវវិញ ដោយស្រប ពេលតែមួយ ។

រួចដាល់សើយពីក្រោម ទៅលើ ចង្កា ត្រង់របៀបហនុមានថ្វាយ ផ្កាព្រះរាម ជំហរជាលក្ខណៈ ខ្លាក្រាប ។

- ក្បិនក្រហម ប្រើមេឈមដោះ ខ្លួន ។
- ក្បិនខៀវ ក្បាច់ខ្លាសង្គ្រប់ជើង ឆ្វេង ជង្គង់ឆ្វេង កែងដៃ ឆ្វេង វាយសង្គ្រប់លើគូ ប្រកួត ជើងស្តាំ ដៃស្តាំប្រុង វាយរំដោះ ។
- ក្បិនខៀវ ប្រើក្បាច់ខ្លា សង្គ្រប់ វាយជង្គង់ហនុមានវែក ពពក តម្រង់គល់ថ្គាម ក្បិនក្រហម ។



- ក្បិនក្រហមប្រើស្លាបសេដាយស ដដែល រងលើកឡើងលើ ដៃស្តាំ ដៃឆ្វេង ប្រើវាយដៃកំរោល ទៅចុងឆ្អឹងជំនីរ ក្បិនខៀវ ស្របនឹង ជើងស្តាំក្បិនក្រហម កាត់ឥសីបោសលាន ត្រង់គន្លាក់ជើងក្បិនខៀវ ឱ្យដួលទៅចន្លោះខ្លួន ។

* មេសេះប្រាយ

* ក្បាច់គោដល់ក្លងនឹម ឬកូលាបសក ឬមច្ឆាត្រលែងខ្លួន

- ស្នៀតនេះច្រើនប្រើដៃនៅពេលជាប់គ្នា ជាក្បាច់ដែលកៀក គេប្រើយកមេបួនទប់ទល់ ។
- ក្បិនក្រហមវាយបកក្បាច់កូលាបសក
- ក្បិនខៀវ រងដូរទឹមកចំពីមុខឡើងលើ វាយបកទាំងដៃ ទាំងជើងចំពីមុខ ។



- ក្បិនក្រហមវាយស្នៀត គង់សិទ្ធ ទៅ ក្បិនខៀវ ។
- ក្បិនខៀវប្រើក្បាច់ហនុមាន តោង មែកឈើ រងដៃក្បិនក្រហម ។
- ក្បិនក្រហមបត់កែង ប្រើ របៀប ដាវសេដាយស វាយ ទៅគល់ថ្គាម ក្បិនខៀវ និងប្រើ កែងជើងញីម្រាម ក្បិនខៀវ បុរាណ ខ្មែរឱ្យឈ្មោះថា "កងចក្រខ្មៅ" ។

* មេពំនួត្នង

* ក្បាច់សេះលុន កាច់ធាក់ កៀកបំបែកស្មាំ



- ក្បិនខៀវហក់ធាក់ក្បិនក្រហម ក្បាច់ក្រញាំជើងខ្លាជាន់ដើមភ្លៅ ក្បិនក្រហម ដៃស្តាំទាំងពីរ ប្រើស្នៀតកណ្តាប់ដៃញីឈ្មោល ក្បិនខៀវប្រើនេះ ប្រើស្នៀតដីរបួងកៀស ក្បិនក្រហម ពីក្នុងចេញក្រៅ រួចប្រើដៃបុកសៀតផ្កាទាំងពីរ ទៅលើក្បិនក្រហម បុរាណខ្មែរឱ្យឈ្មោះថា "ឥសីបំបែកភ្នំ" ។

*** ក្បាច់ព្រយុងពោធិ**

*** មេជំហារទន្សាយ**



- ក្បិនក្រហម ប្រើមេជំហារទន្សាយ ។
- ក្បិនខៀវ ប្រើក្បាច់ព្រយុងពោធិ ហក់ឈរទប់ចុងជើងតោងឡើង ត្រៀមពុះកែងដៃពីលើ រុលចុះក្រោមវះកណ្ដាប់ដៃនឹងកែងដៃ តាមដើមទ្រូង គូប្រកួត ។

* ក្បិនខៀវ ប្រើកែងដៃទាំងពីរបុកជ្រែងកាំបិត ក្បិនក្រហម នោះបុរាណខ្មែរឱ្យឈ្មោះថា "ទេពប្រណម្យ" ។

*** មេខ្មែរកាត់មេពីរបកក្បួន**

- ក្បិនក្រហម វាយដៃកំរោលបួនជ្រុង តម្រង់ផ្ទៃមុខ ក្បិនខៀវ ស្របនឹងទាត់ភ្នែនឥសីទៅដើមភ្លៅក្បិនខៀវ ។
- ក្បិនខៀវ ប្រើស្នៀតឥន្ទ្រីជើងបី ដោយក្បិនខៀវថ្ពក់ជើងក្បិនក្រហម ទាញឱ្យឱនជើងឆ្វេងទាត់ពីក្រោមកំភួនជើង បុរាណខ្មែរឱ្យឈ្មោះថា "ហនុមានហោះកាត់ព្យុះសមុទ្រ" ។



# លោកគ្រូ សឺត អ៊ុង អាយុ ៦០ ឆ្នាំ



- លោកគ្រូ នៅចេះចាំក្បា
គុនដៃ ដូចជា មេមួយ មេពី
មេបី ក្បាច់ល្បុក្កតោ ពិសេស
ជំនាញដំបងវែង ។

- លោកគ្រូ បានហាត់រៀន
ឪពុកគាត់ផ្ទាល់ រហូតបញ្ចប់
នៅ ឆ្នាំ១៩៧០ នៅភូមិព្រៃថ្ន
ឃុំព្រៃថ្នង ស្រុកកំពត ខេត្ត
កំពត ។

* មេសមបុកក្លូង

* ក្បាច់ខ្លាឃើញចំណី

* ខ្វែងមេមួយគងស្ពាំ

* ស្លៀតបកសំបកឈើ

- ក្បិនក្រហមប្រើដៃកំរោល បួនជ្រុង កាត់ តម្រង់មុខ ក្បិនខៀវ ។

- ក្បិនខៀវប្រើស្លៀត កាច់ សង្រែក រងយកបាតជើង អារក្សទះចំហៀង ក្បាល ជង្គង់ស្របនឹងវាយគងសិរទ្ធ ពីកញ្ចឹង-កក្រោយ ទៅលើ ក្បិនក្រហម ។



### * មេព័ន្ធទប់ក្បួន បំបែកមេពីរខ្មែរ

### * ក្បាច់បក់ស្រកានាគ



- ក្បិនខៀវ ប្រើមេបញ្ឆោតជង្គង់ឆ្វេង វាយដៃស្ដាំ ប្រើមេបីបញ្ឆោតជង្គង់ឆ្វេង ។
- ក្បិនខៀវ ប្រើជង្គង់ហនុមានទល់មេឃ ស្របនឹងដៃសរឥន្ទជិត បញ្ឆោតឱ្យក្បិនក្រហមប្រើគងសិទ្ធ ទាំងពីរវាយបង្ក្រាប ។ ក្បិនខៀវវាយលុកដាល់ "ច្រកពង្ស" តម្រង់ចង្កាក្បិនក្រហម មួយក្បាច់នេះ បុរាណខ្មែរឱ្យឈ្មោះថា "ព្រះរាមចូលកោដិបញ្ឆោតនាងសីតា" ដែលជាក្បាច់បញ្ឆោតមួយដ៏ពិសេស ដែលនិយមប្រើគ្រប់មេគុន ។

### * មេព័ន្ធបុកបំបាក់

### * ក្បាច់វាយកែង ទប់បំបាក់ មេមួយ



- ក្បិនខៀវ វាយកណ្ដាប់ដៃកំរោលបួនជ្រុង បោះនាគជើងចេញក្រៅ ជាសន្ទុះក្អែកដៃឆ្វេងរងចាប់ បុរាណខ្មែរឱ្យឈ្មោះថា "ហនុមានបាំងព្រះអាទិត្យ" ដៃស្ដាំទះផ្ទៃមុខក្បិនក្រហម ។ ក្បិនក្រហម ចាប់កដៃក្បិនខៀវជាប់ ។ ក្បិនខៀវ បត់កែងដៃបុកសរព្រះរាម រួចកាប់ដើមដៃក្បិនក្រហមបន្ថែម ស្របពេលតែមួយនឹងការប្រើជើងស្ដាំធាក់គន្លាក់ជើងក្បិនក្រហម បោកឱ្យផ្ងារថយក្រោយ ។

* មេប្ចូនភាត់មេពីរថ្ងូងក្នុង
* ក្បាច់ប៉ើងបំបុក



- ក្បិនក្រហម ប្រើកែងព្រះរាម ហួតព្រះខ័ន ។
- ក្បិនខៀវ ប្រើស្មៀតក្រញាំខ្លាជ្រោងដើមដៃក្បិនក្រហម ។ រួចវាយក្បាច់ ហនុមានថ្វាយផ្កាព្រះរាម ហួតបកកែងសើយឡើងលើ បុរាណខ្មែរឱ្យឈ្មោះថា "កែងសីតាចាប់ផ្កាយ" ។



* មេដៃចងដៃ
* ក្បាច់កាច់ស្លាបមាន់ ឬ ស្វាចងត្រកួត
* ខ្លះហៅថាក្បាច់តាព្រហ្មចងខ្លា

- ក្បិនក្រហមដាល់ត្រង់ "សរឥន្ទជិត" ដាល់ត្រង់សំដៅផ្ទៃមុខក្បិនខៀវ ។
- ក្បិនខៀវ ធាក់ចេញក្រៅ យកដៃស្តាំលូកខ្ទាស់កៀបពីលើ ដៃឆ្វេងក្បិនខៀវចាប់ច្បាមសក់ ដៃស្តាំលូកចាប់ដៃឆ្វេងក្បិនក្រហម ទាញរឹតបញ្ចូលគ្នា ស្របពេលតែមួយ ដោយយកជង្គង់ស្តាំ គប់គន្លាក់ជើងក្បិនក្រហម សង្កត់ឱ្យដួល ផ្ងារមកក្រោយ ។ មួយក្បាច់នេះ បុរាណខ្មែរឱ្យឈ្មោះថា "តាព្រហ្មចងខ្លា" ។

**✲ មេធប់ក្អួខ**

**✲ ក្បាច់ក្របី ឬតួរភី ឬក្របីរុលនឹម**



- ក្បាច់នេះប្រើមេពីររុលវាយកែង ឡើងជង្គង់ជាប់ៗគ្នា ។
- ក្បិនក្រហម ប្រើកែងតួរភី នឹងជង្គង់ ហនុមានទល់មេឃ ស្របពេលតែមួយ ។
- ក្បិនខៀវ ប្រើកែងសរព្រះរាម រងកែង តួរភី រួចអុកទម្លាក់មកចុងភ្លៅ ក្បិនក្រហមកែងព្រះរាម ជ្រែកធរណី ទម្លាក់ជើងស្តាំ ។ ក្បិនខៀវ ទាត់ជង្គង់ស្តាំ ហនុមានវែកពពក មកចុងឆ្អឹងជំនីរក្បិនក្រហម ។



**✲ មេសមភាត់ក្អួខ**

**✲ ក្បាច់គខព័ន្ធធប់មេបី**

**✲ ក្បាច់ក្របីបុកនឹម**

- ក្បិនខៀវប្រើស្នៀតដីរបួងវែង ទាញ-កដៃទាំងពីរ បោះជង្គង់ឆ្វេង វាយក្បាច់ ជង្គង់ហនុមាន បំបាក់ភ្នំទៅលើកញ្ចឹង - ក ក្បិនក្រហម "ពីចំហៀង" ។

* មេគ្រូបដោះមេពីរ
* ក្បាច់គោជល់ដោះនឹម



- ក្បិនក្រហម យកដៃទាំងពីរ សង្កត់ បង្ក្រាបដៃក្បិនខៀវទាំងពីរ ។
- ក្បិនខៀវ ប្រើដៃគាស់ កម្លាំងស្រប ដៃទាំងពីរនឹងស្មាស្តាំ តោះពីក្រោយ ស្មាឆ្វេង ក្បិនក្រហម អង្កុញដៃគាស់ឡើងលើ វាយកែងស្របពីក្រោមដៃឆ្វេងក្បិនក្រហម ដោយបុកកែងចូលប្រឡោះគ្លៀក បុរាណខ្មែរឱ្យឈ្មោះថា "កែងនាយសាហាយបោយខ្យល់" ។

* មេថ្វងដោះមេមួយ
* ក្បាច់ទប់ចង្កូមខ្លា
* ហនុមានបំបាក់ភ្នំភ្លើង

- ក្បិនក្រហម លូកដៃដាល់ (សរឥន្ទជិត) ឬមេសមក្នុង ។
- ក្បិនខៀវយកដៃទះបញ្ចេញស្របពេលតែមួយនឹងជើងលោតខ្វាំ ជាន់ដើមភ្លៅក្បិនក្រហម ដៃឆ្វេងមួលដៃលោតវាយជង្គង់បង្វិលកាប់បំបាក់ភ្នំក្បិនក្រហមពីខាងក្រោយ ។



*** មេព័ន្ធរេចពីមុខ បំបែកឆ្វេងស្តាំ**

*** ក្បាច់មាន់គ្រងកូន**



- ក្បាច់នេះប្រើមេមួយ វុលពីមុខដូចគ្នា កាត់ក្រោម វាយលើ ទាំងឆ្វេងទាំងស្តាំ ។ ក្បាច់នេះច្រើនប្រើកណ្តាប់ដៃ ។
- ក្បិនក្រហម ប្រើកណ្តាប់ ដៃកំរោលបួន ជ្រុងគប់ក្បាល ជង្គង់ក្បិនខៀវ វាយទម្លាក់ ក្បាច់សងផ្កាព្រះរាម ដៃស្តាំវាយសើយចង្កា ក្បិនខៀវ ។
- ក្បិនខៀវ ប្រើក្បាច់តួរភី គ្រលែងស្មែងវាយ បង្ក្រាប ហើយវាយកែងទាំងសងខាង ទៅលើក្បិនក្រហមចំណុចគល់ថ្គាម ។

*** មេខ្វែងពីរជាន់**

*** ក្បាច់ត្បែងរីតចំណង**

*** ក្បាច់កាច់ស្លាបមាន់**



- ក្បិនក្រហម ប្រើក្បាច់ក្រញ៉ាំ ដៃខ្លាចាប់ចំណី ។
- ក្បិនខៀវ បោះជើងចូលដាល់ (ជើងស្តាំ ដៃស្តាំ) ។
- ក្បិនក្រហម យកដៃឆ្វេងផាត់ ទះ ចាប់បង្ក្រាប ដៃស្តាំ ។ លូក ចាប់គន្លាក់កែងដៃ យកមេដៃ ចុចចំណុចជីពចរ បោះជើងឆ្វេង ចូល ស្របនឹងការរុញដៃឆ្វេងចូល ខ្ទាស់ពីក្រោយ ខ្នងក្បិនខៀវ ដៃស្តាំច្បាម-កពីក្រោយ ។ ជើងក្បិនក្រហម ធាក់គន្លាក់ជើងស្តាំក្បិនខៀវ ទាញឱ្យក្បិនខៀវផ្ងារ មក ក្រោយ យកជង្គង់ឆ្វេងសង្កត់ជើងឆ្វេង ដៃឆ្វេងសង្កត់ជើងឆ្វេង ក្បិនខៀវ ។

* មេប្ញកស្ម បំបែកក្រញាំជើងឆ្កែ

* ក្បាច់ជំហរគ្រុឌ



- ក្បិនក្រហម ដាល់កណ្តាប់ដៃសរឥន្ទជិត បុកចំចង្កា ក្បិនខៀវ ។
- ក្បិនខៀវ ប្រើក្បាច់ក្រញាំបិសាចទះបំបុកកណ្តាប់ដៃ ក្បិនក្រហម (ដៃឆ្វេង) ដៃស្តាំ លូកខ្ទាស់ពីក្រោម - កដៃឆ្វេង លាតចាប់កដៃ បោះជំហាន ស្តាំចូលរុញកាច់តាមកម្លាំងញាក់ របស់ក្បិនក្រហមវើ ។ មួយក្បាច់នេះបុរាណខ្មែរឱ្យឈ្មោះថា "ហនុមានចាប់សរឥន្ទជិត" ។

* មេប្អូនវល្លិព័ន្ធ

* ក្បាច់បំបែកពោះញីឈ្មោល

-ក្បិនក្រហមប្រើស្នៀតហនុមានថ្វាយ ឃុំព្រះរាម ។ ក្បិនខៀវប្រើសរនាគព័ន្ធ ដៃទាំងពីរទះបង្ក្រាបពីលើក្បិនខៀវ ទាំងពីរច្បូតដៃទាំងពីររបស់ ក្បិនក្រហមមកចាប់ថ្លើមដៃមួលពីក្នុងចេញក្រៅផ្ងារឡើងលើយកជើងស្តាំទាត់ជើងខ្មោច (ទាត់ក្តិលជើង) ចំណុចចុងដង្ហើម គ្រលាស់កែងជើង ទាត់សើយចង្កា (ច្រតឥស្សី) បុរាណខ្មែរឱ្យឈ្មោះថា "ឥន្ទ្រីហែកចំណី" ។



*** មេចង្វាយផ្គៅ**

*** ក្បាច់ទ្រលើរលំ**



- ក្បិនខៀវ ប្រើមេចង្វាយ ផ្គៅវិលបង្វិលសង្កត់ ។
- ក្បិនក្រហម ប្រើស្មាទ្រដៃស្តាំទប់គោងបង្វិល កៀវទម្លាក់ចុះ ។
-ក្បាច់នេះប្រើមេបីទាំងអស់ គ្នាក្បិនខៀវ ទាត់ព្យុះសមុទ្រតម្រង់ចំណុចកញ្ចឹង- កក្បិនក្រហមដកជើងឆ្វេងស្រប នឹងជើងឆ្វេងលើករងបិទស្រប នឹងដៃស្តាំរុញប្រមុខ ទប់ក្បាលជង្គង់ក្បិនខៀវ ។ ដៃឆ្វេងក្បិនក្រហម ដៃលរង គ្រលៀស ចាប់ពីលើ-កជើង ស្របពេលដៃលទាញមួលជើងឱ្យក្រឡាប់ចុះមកមុខ ដោយបោះជំហានស្តាំចូលកាច់ឱ្យក្បិនខៀវ ដួលលុតជង្គង់មកមុខ ជើងឆ្វេងទាត់ព្យុះសមុទ្របំបាក់ក្បិនខៀវពីក្រោយ បុរាណខ្មែរឱ្យឈ្មោះថា "ចង្វាយផ្គៅ" ។

*** មេឆប់ឆ្វេង បំបែកស្តាំ**

*** ក្បាច់ជ្រំជើងសេះ**



-ក្បិនក្រហម លើកដាល់ដៃកំរោលបួនជ្រុង ( ដៃស្តាំ) ។
-ក្បិនខៀវយកដៃឆ្វេង ផាត់កាប់ទម្លាក់ ក្បិនក្រហម ដាល់ដៃឆ្វេងមួយដៃទៀត ក្បិនខៀវរងរបៀបសរព្រះរាម រួចហើយញសកែង បុកគន្លាក់ដៃ កែងដែលបុកនោះបុរាណខ្មែរហៅថា "ព្រះរាមជ្រែកធរណី" បុកគន្លាក់ដៃក្បិនក្រហមហើយអង្កុញដៃ ខោកផ្ទៃមុខ ក្បិនក្រហម រួចហើយគោះកែងពីក្រោមចង្កា ។ មួយស្នៀតនេះបុរាណខ្មែរឱ្យឈ្មោះថា "សេះជ្រំជើងមួយ" ។

## * មេពីរកាត់ឆ្វេង បំបែកស្តាំ

## * ក្បាច់ធាក់បំបើង



-ក្បិនខៀវ ស្ទុះវាយគងសិរិទ្ធ ដៃឆ្វេង ក្បិនក្រហមយកដៃគងសិរីទ្ធ វាយបង្ក្រាប ស្របនឹងជើងឆ្វេងធាក់កណ្តៀតក្អមក្បិនខៀវ ដៃរងរបស់ក្បិនក្រហមលាតបាតដៃចាប់កដៃក្បិនខៀវស្រប ពេលតែមួយ ក្បិនក្រហមលាត ជើងស្តាំ លោតធាក់ចុងដង្ហើម ទាញផ្តួល ទាត់បំផ្លោងគ្រវាត់ ក្បិនខៀវឱ្យប៉ើងរំលងក្បិនក្រហម ។ មួយមេគុននេះបុរាណខ្មែរឱ្យឈ្មោះថា "ស្វាយោលទោង" ។

## * មេពាច់ឆែកឬភារោមមេ

## * ក្បាច់១២កាត់យក៨

-ក្បិនក្រហម ចូលទៅច្បាម-កក្បិនខៀវ ទាត់ជង្គង់ហនុមានទាល់មេឃ ។ ក្បិនខៀវ ប្រើកែង ជ្រិបុកកែងទាំងពីរលើចុងភ្លៅក្បិនក្រហម បុកកណ្តាប់ដៃទាំងពីរ សើយចង្កា ។ មួយមេគុននេះ បុរាណខ្មែរ ឱ្យឈ្មោះថា "តួរភីបំបែកដំបូក" ។



*** មេស្រង៉ៃពេន**

*** ក្បាច់ពង្សសក្តិ១២ ភាត់យក៨**



-ក្បិនខៀវលោតទាត់ជង្គង់ស្តាំ ក្បិនក្រហម មូលដៃបុកកែង ទម្លាក់ ជង្គង់ក្បិនខៀវ ។ ក្បិនខៀវលូកដៃឆ្វេងដាល់មួយដៃទៀត ។ ក្បិនក្រហមមូលដៃ កៀសពីក្នុងចេញក្រៅ រងដៃដាល់របស់ ក្បិនខៀវរួចហើយ មូលដៃដែលរងនោះ រុញដាល់ ច្រកពុង ក្បិនខៀវគ្រលែងកែង តួរភីមួយកែងទៀត ។ មួយមេគុននេះ បុរាណខ្មែរឱ្យឈ្មោះថា "ស្រង៉ៃពេន" ។

*** មេមហាហ៊ឹង្សទ្រមេឃ**

*** ក្បាច់សងព្រះអាទិត្យ**



-ក្បិនខៀវ ហក់វ៉ៃដៃកំភោល បួនជ្រុង សំដៅគល់ថ្គាមរបស់ក្បិនក្រហម ។ ក្បិនក្រហម ដក ជំហានឆ្វេងថយបន្តិច កាប់គង សរីទ្ធបំបាក់ដើមដៃក្បិនខៀវ ។ ក្បិនក្រហម បង្វិលជើងឆ្វេង ដែលដក បង្វិលខ្លួនបុកកែងខ្លា សំកាំង បុកកែង ស្របដងខ្លួន ចំ ចុងដង្ហើម រួចហើយគ្រលែងកែងស្តាំកាប់ពីលើ បញ្ឆិតទៅក្រោម សំដៅគល់ថ្គាមក្បិនខៀវ ។ មួយមេគុននេះ បុរាណ ខ្មែរឱ្យឈ្មោះថា "មច្ឆាគ្រលែងខ្លួន" ។

* មេក្រោមបីចំហៀង

* ក្បាច់ស្វាក្រចាប់ ឬស្វាបេះពង



* ជំហរខ្លាក្រាប

-ក្បិនខៀវ ទាត់ព្យុះសមុទ្រ

-ក្បិនក្រហម លោតសន្ទុះខ្លា បោះជើងស្តាំ ស្របនឹងដៃស្តាំ បោះចូលពីក្រោមជើងទាត់ របស់ ក្បិនខៀវ ស្របនឹងដៃ ដាល់ផង បន្ថែម ក្រឡាប់ដៃ វាយកែង បេះយកពង ។ បុរាណខ្មែរឱ្យឈ្មោះថា "ស្វាបេះសេដា ថ្វាយព្រះរាម" ។

* មេសោមដាវ ឬគាថាបង់បត់

* ក្បាច់សោមថ្វាយគ្រូ ១២កាត់យក៨



-ក្បិនខៀវ វាយសរឥន្ទជិត បង្ក្រាបឃុំ ក្បិនក្រហម ។

-ក្បិនក្រហម ចាប់គាស់បំបើុង ដៃដែល សង្កត់ឡើងលើ គ្រលែងកែងគាស់ដាល់ច្រកពុងសងវិញ គាស់ថ្គាមដាល់ ដៃស្តាំបន្ថែមមួយទៀត ចំណុចចង្កា គ្រលាស់កែងសើយឡើង លើ បញ្ចិត ។បុរាណខ្មែរឱ្យឈ្មោះថា "សរឥន្ទជិតសម្តែងឫទ្ធិ" ។

* មេលើកគ្រូ
* ក្បាច់មហាហ៊ីឡុកាត់ដែក



-ក្បិនខៀវ ទាត់ភ្នែនឥសីសំដៅគាល់ថ្គាមក្បិនក្រហម ។
-ក្បិនក្រហមលើកដៃរង បិទចំហៀងខ្លួន មួលដៃត្រកងបោះជើងឆ្វេងចូល ស្របនឹង ដៃឆ្វេងរុញ ឃុំក្បិនខៀវ វាយកែងចំហៀងថ្គាម កែងមួយរបៀបនេះបុរាណខ្មែរឱ្យឈ្មោះ ថា "សេដាយសបាក់ស្លាប" ។

* មេទប់ជាន់ថ្លក់
* ក្បាច់ជន្លង់ហោះហែកស្គាំ

-ក្បិនខៀវ លើកជើងក្រញាំខ្លាជាន់គាស់ភ្លៅ ក្បិនក្រហមស្របនឹងដៃដាល់ បញ្ឆោតឱ្យ ។
-ក្បិនក្រហមកៀសចាប់ស្របនឹងដៃ ក្បិនក្រហមដាល់សងវិញ គាស់ចាប់ដូចគ្នា ក្បិនខៀវលោតជើងស្គាំ ហក់វាយជង្គង់បាក់ភ្នំ ។ បុរាណខ្មែរឱ្យឈ្មោះថា "ហនុមានបំបាក់ភ្នំ" ។



## ✱ មេជ្រងកាត់ទ្វារ៨

## ✱ ក្បាច់រាហ៊ូទ្រមេឃ ឬទប់ជើងសេះ



-ក្បិនក្រហម ទាត់ព្យុះសមុទ្រ បញ្ឆោត ឱ្យក្បិនខៀវចាប់បាន ជើងក្បិនក្រហម រួចហើយដាល់ បុកសងវិញ ។ក្បិនក្រហម យក ដៃឆ្វេងកាត់សន្ទាក់ ស្របនឹងដៃ ស្តាំវាយកែងស្វាបៀមបាយ ។ បុរណាខ្មែរឱ្យឈ្មោះថា "រាហ៊ូទ្រ មេឃ" ។

## ✱ មេឥសីដកដាវ

## ✱ ក្បាច់គងជ្រងព្រះអាទិត្យ



-ក្បិនក្រហមទាត់ជើងខ្មោច (ទាត់ឈ្លូសក្តោលជើង) ។

-ក្បិនខៀវងាកធាក់ យកដៃ ឆ្វេង ទ្រជើងដៃស្តាំដែលដាល់ ស្រប នឹងជើងទាត់ ។

-ក្បិនខៀវមុខគេចដៃដែល ដាល់ យកដៃស្តាំជ្រោង ដើមដៃ ស្របបោះជើងស្តាំចូល ពី ក្រោយជន្ទល់ ក្បិនក្រហមបោក ផ្តួលឱ្យដួលផ្ងារទៅក្រោយ ។ បុរាណខ្មែរឱ្យឈ្មោះថា "គងជ្រងព្រះអាទិត្យ" ។

## * មេធប់ធាក់ជ្រូងដង្កៀប
## * ក្បាច់ធប់ខ្ទួងកាត់មេ៨




-ក្បិនខៀវ ធាក់ភ្លៅក្បិនក្រហម ប្រុងជាន់ឡើង។ -ក្បិនក្រហមយកដៃកំរោលបួនជ្រុង កាប់គាស់ពីក្នុង ចេញក្រៅ ដាល់សង ក្បិនខៀវ ។ ក្បិនខៀវ យកដៃ ខ្វែងជ្រោង ក្បិនក្រហមបោះជើងចូលខោក ជំទាស់ ដោយប្រើកែងដៃស្តាំខោក ជំទាស់ជើង ក្បិនខៀវ ឱ្យ ដួលផ្ងារក្រោយ ។ បុរាណខ្មែរឱ្យ ឈ្មោះថា "វលកទប់ច្រាំង" ។




## * មេពន្លំពុះឆ្វេង រំលំស្តាំ
## * ក្បាច់លើកអង្រែធប់ចង្កូមខ្លា

-ក្បិនខៀវទាត់ធាក់មេជើង (ចង្កុលខ្មោច) ។ ក្បិនក្រហម ចូល ស្របពីក្នុង ជើងទាត់ វាយកែងឆ្វេងឱ្យក្បិនខៀវ រងគ្រលាស់កាប់ កណ្តាប់ដៃតម្រង់កញ្ចប់មាត់ ។ បុរាណខ្មែរឱ្យ ឈ្មោះថា "ក្បាច់លើកអង្រែទប់ ចង្កូមខ្លា" ។